គណៈកម្មាធិការ
សហប្រតិបត្តិការដើម្បីកម្ពុជា
Cooperation Committee for Cambodia
Comité de Coopération Pour le Cambodge

Brot für die Welt

# វេទិកាសៀនសូត្រស្ដីពី ឧបករណ៍មិនបង្កទំនាស់

# Do No Harm Learning Forum

០៦ តុលា ២០២០

# គោលបំណង

- អ្នកចូលរួមនឹងយល់ពីអ្វីជាឧបករណ៍មិនបង្កទំនាស់ (Do No Harm) និងបង្កើនការស្វែងយល់ពីការអនុវត្តកម្មវិធី ជាពិសេសការពិនិត្យទៅលើ កត្តាបែកបាក់ និងកត្តាផ្សាភ្ជាប់ (Dividers & Connectors)

# កម្មវិធីឧបករណ៍មិនបង្កទំនាស់ និង ការយកចិត្តទុកដាក់នឹងទំនាស់

កម្មវិធីបានទទួលការគាំទ្រថវិកាពីអង្គការ Bread for the World (BfdW) តាំងពីឆ្នាំ ២០១៥។ ក្រុមការងារឧបករណ៍មិនបង្កទំនាស់កម្ពុជាក៏បានបង្កើតឡើងក្នុងឆ្នាំ ២០១៤ ផងដែរ។ សម្រាប់វគ្គទី២ នេះ កម្មវិធីទទួលថវិកាគាំទ្រពី BfdW រយៈពេល ៤០ខែ (កញ្ញា ២០១៧ - ធ្នូ ២០២០)។

## គោលដៅ

អង្គការសង្គមស៊ីវិលកម្ពុជា អនុវត្តកម្មវិធីរបស់ខ្លួនដោយមានការយកចិត្តទុកដាក់នឹងទំនាស់ ដោយមិនមានបង្កទំនាស់ដល់សហគមន៍។

## គោលបំណង

ត្រឹមឆ្នាំ ២០២០ អង្គការសង្គមស៊ីវិលកម្ពុជា ធ្វើការកែលម្អផែនការគម្រោង ការអនុវត្ត និង ប្រព័ន្ធត្រួតពិនិត្យរបស់ខ្លួន ដោយបានប្រើប្រាស់ក្របខណ្ឌការងារឧបករណ៍មិនបង្កទំនាស់។

# សកម្មភាពសំខាន់ៗរបស់គម្រោង

សិក្ខាសាលាផ្សព្វផ្សាយ → វគ្គបណ្តុះបណ្តាលគ្រូបង្គោល ៥ថ្ងៃ → សិក្ខាសាលាអនុវត្ត ៥ថ្ងៃ → ការបង្វឹក និងផ្តល់យោបល់ ៦ថ្ងៃ → បញ្ជ្រាបក្នុងយុទ្ធសាស្ត្រកម្មវិធី

- *ថវិកាគាំទ្រពី BfdW ៥ ស្ថាប័ន/ឆ្នាំ*
- *សរុប ៣៧២០ ដុល្លារ/ស្ថាប័ន*

# Do No Harm Cambodia Team (DNHC)



**Alain Fressanges**
Advisor,
KCD
alain.fressanges@gmail.com
012 216 386



**Sim Sambath**
Program Manager,
Mission Alliance
sambath@nmakh.com
012 836 650



**Luy Theary**
DNHC Coordinator,
CCC
theary.luy@ccc-cambodia.com
012 339 027



**Srey Sotheavy**
Executive Director,
ACT
director@act.org.kh
017 990 371



**Toy Monireth**
Freelance
monirethtoy@gmail.com
017/098 728 895



**Lav Bunrithy**
Senior Consultant,
VBNK
bunrithy@vbnk.org
012 925 799



**Keo Navin**
Organizational Assistant,
SADP
navin@sadp-asia.org
092 444 563



**Chen Sochoeun**
RMD Manager,
CCC
sochoeun.chen@ccc-cambodia.com
012 904 554



**Vuthy Victory**
Freelance
victory.7seven7@gmail.com
077 393 800



**Kry Suy Heang**
Executive Director,
WPM
Suyheangsn@gmail.com
012 582 763



**Tep Chanbora**
Program Manager,
ForumSyd
tep.chanbora@forumsyd.org
012 929 352



**Chhiv Kimsrun**
Freelance
kimsrunch@gmail.com
012 959 647



**Lim Phai**
Program Director,
VBNK
phai@vbnk.org
012 859 226



**Chhoeun Thavy**
Freelance
thavy1996@gmail.com
012 932 357



**Menh Navy**
Freelance
menhphanavy@gmail.com
011 958 979



**Russell Peterson**
Freelance
N/A
N/A



**Tourt Chamroen**
Principal Consultant,
VBNK
chamroen@vbnk.org
011 961 318



**Phann Chandara**
Project Officer,
ForumZFD
dara.chanda@gmail.com
089 998 464



**Chhit Muny**
Consultant,
VBNK
muny@vbnk.org
089 454 615

# អ្វីទៅជាទំនាស់ (Harm)?

- យើងចង់ប្រើភាសាជាក់លាក់ថា "ផលជះអវិជ្ជមាន លើកត្តាផ្សារភ្ជាប់ *រវាង ក្រុម ក និង ក្រុម ខ"* ឬ "ផលជះវិជ្ជមាន លើកត្តាបែកបាក់ រវាង ក្រុម គ និង ក្រុម ឃ" ។

# ករណីសិក្សា

សហគមន៍មួយ ប្រកបរបរចិញ្ចឹមជីវិតពឹងផ្អែកលើការនេសាទ។ ទោះយ៉ាងណា ពួកគេជួបបញ្ហាជាច្រើនជាមួយការនេសាទខុសច្បាប់ ជាពិសេសការនេសាទខុសច្បាប់ពីមនុស្សនៅខាងក្រៅសហគមន៍។ អង្គការមិនមែនរដ្ឋាភិបាល មួយ បានផ្តល់មូលនិធិដល់សហគមន៍ដើម្បីធ្វើល្បាត។ ភាគច្រើននៃថវិការបស់អង្គការក្រៅរដ្ឋាភិបាល បានទៅមនុស្សមួយចំនួនតូចដែលមានទូកធំៗតែប៉ុណ្ណោះ។ លទ្ធផលនៃការល្បាតនេះ បានធ្វើឱ្យការនេសាទខុសច្បាប់ធ្លាក់ចុះ ប៉ុន្តែនៅពេលដែលគម្រោងអង្គការក្រៅរដ្ឋាភិបាលបានបញ្ចប់ ប្រាក់ចំណូលសម្រាប់ប្រជាជនដែលមានទូកធំៗ ក៏បានបញ្ចប់ដែរ។ ប្រជាជនដែលមានទូកធំៗ ពួកគេបានខ្ចីប្រាក់ពីធនាគារ ដោយពឹងផ្អែកលើប្រាក់ចំណូលពីអង្គការក្រៅរដ្ឋាភិបាលទាំងស្រុង។ ដូចនេះនៅពេលគម្រោងបានបញ្ចប់ ប្រជាជនដែលមានទូកធំៗទាំងនោះ ចាប់ផ្តើមនេសាទខុសច្បាប់ដើម្បីរកប្រាក់ចំណូល មកជំនួសចំណូលដែលពួកគេធ្លាប់ទទួលបានពីអង្គការក្រៅ រដ្ឋាភិបាល ដើម្បីសងបំណុលទៅធនាគារវិញ។

នៅពេលដែលគម្រោងកំពុងដំណើរការប្រជាជនដទៃនៅក្នុងសហគមន៍ មានអារម្មណ៍ថាការល្បាត "មិនមែនការងាររបស់ពួកគេ" ដូច្នេះពួកគេមិនបាច់ធ្វើវាទេ (ពួកគេនិយាយថា វាជាតួនាទីរបស់ម្ចាស់ទូកធំៗដែលគាំទ្រដោយអង្គការក្រៅរដ្ឋាភិបាល)។

ការវាយតម្លៃលទ្ធផលគម្រោង បានធ្វើរួចរាល់នៅចុងបញ្ចប់នៃគម្រោងនេះ បាននិយាយថាគម្រោងនេះទទួលបានជោគជ័យយ៉ាងខ្លាំង ប៉ុន្តែ ៦ខែ បន្ទាប់ពីគម្រោងបានបញ្ចប់ ការនេសាទខុសច្បាប់ មានការកើតឡើងច្រើនជាងមុនពេលគម្រោងរបស់អង្គការក្រៅ រដ្ឋាភិបាលបានចាប់ផ្តើមទៅទៀត។

## តើមាន (Harm) បង្កឡើងដោយអង្គការមិនមែនរដ្ឋាភិបាលឬទេ?

# ឧបករណ៍មិនបង្កទំនាស់ (Do No Harm)

- តើជំនួយអាចធ្វើឲ្យស្ថានភាពទំនាស់កាន់តែធ្ងន់ធ្ងរឡើង ឬ កាន់តែថយចុះ តាមវិធីដែលយើងធ្វើការ និងជម្រើសដែលយើងបានជ្រើសដោយរបៀបណា?
- តើអ្វីខ្លះជាឥទ្ធិពលសំខាន់ៗ របស់ជំនួយក្នុងបរិបទផ្សេងគ្នា? និង តើអ្វីខ្លះជាឥទ្ធិពលរបស់បរិបទទៅលើការងារផ្តល់ជំនួយ?
- តើអ្វីខ្លះជាវិធីសាស្ត្រអនុវត្តជាក់ស្តែង ដើម្បីបញ្ចូលការយកចិត្តទុកដាក់នឹងទំនាស់ទៅក្នុងការវិភាគបរិបទ និងទៅក្នុងការរៀបចំកម្មវិធី ការអនុវត្ត ការត្រួតពិនិត្យ និងវាយតម្លៃ?
- នៅក្នុងការលើកកម្ពស់គណនេយ្យភាព និងការរៀនសូត្រនៅគ្រប់កម្រិតចាប់តាំងពីអ្នកផ្តល់សេវា រហូតដល់សហគមន៍មូលដ្ឋាន និងទៅដល់ការិយាល័យកណ្តាល និងម្ចាស់ជំនួយ តើការយកចិត្តទុកដាក់នឹងទំនាស់ អាចត្រូវបានត្រួពិនិត្យ និងវាយតម្លៃប្រកបដោយប្រសិទ្ធភាពតាមរបៀបណា?

# ឧបករណ៍មិនបង្កទំនាស់ (Do No Harm)

- ឧបករណ៍មិនបង្កទំនាស់ គឺជាវិធីសាស្ត្រមួយដែលអាចធ្វើការព្យាករណ៍ទុកជាមុន ហើយមានគោលបំណងបង្កើនការយល់ដឹងពីរបៀបដែលជំនួយអាចបង្កើតឲ្យមានជាសកម្មភាពទំនាស់។ ឧបករណ៍មិនបង្កទំនាស់ បង្កើនការអនុវត្តនៃ**ការយកចិត្តទុកដាក់នឹងទំនាស់** (Conflict Sensitivity) ក្នុងគោលនយោបាយ និងប្រតិបត្តិការក្នុងការផ្តល់ជំនួយ ក្នុងគោលបំណងកាត់បន្ថយផលជះអវិជ្ជមានជាអប្បរមា និងបង្កើនផលជះវិជ្ជមានជាអតិបរមា។

# ព្រឹត្តិការណ៍នៅរ៉្វាន់ដា







**ការសន្និដ្ឋាន**

ការសម្លាប់រង្គៀលនៅរ៉្វាន់ដា គឺជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិមួយដ៏អាក្រក់បំផុត ដែលក្នុងរយៈពេល ១០០ថ្ងៃ មានមនុស្សជាង ៨០០.០០០នាក់ ត្រូវបានសម្លាប់។ សោកនាដកម្មនេះ បានកន្លងផុតទៅហើយក្តី ប៉ុន្តែប្រវត្តិសាស្ត្របានកត់ត្រាពីការឈឺចាប់ និងផលប៉ះពាល់ដែលបានកើតឡើង។


Hippocratic Oath
Medical practice
DO NO HARM
HOW AID CAN SUPPORT PEACE—OR WAR
Mary B. Anderson
90's - Mary Anderson
Humanitarian action
CDA
Extension of the approach
Conflict Sensitivity
Do No Harm
DO NO HARM WORKSHOP
CDA
One principle and much debate
Overused
Avoid causing harm
As from 2014:
No longer restricted to humanitarian aid
Development, various policies

# បរិបទ អន្តរាគមន៍



# មេរៀនទាំង ៦ នៃឧបករណ៍មិនបង្កទំនាស់ (DNH)

1. នៅពេលដែលអន្តរាគមន៍ណាមួយចូលទៅក្នុងបរិបទមួយ វាក្លាយជាផ្នែកមួយនៃបរិបទនោះ



# មេរៀនទាំង ៦ នៃឧបករណ៍មិនបង្កធំនាស់ (DNH)

2. រាល់បរិបទទាំងអស់ត្រូវបានកំណត់លក្ខណៈដោយកត្តា២ គឺ កត្តាបែកបាក់ និង កត្តាផ្សាភ្ជាប់

| បរិបទ | | |
|---|---|---|
| កត្តាបែកបាក់ | អន្តរាគមន៍ | កត្តាផ្សាភ្ជាប់ |
| | | |

# មេរៀនទាំង ៦ នៃឧបករណ៍មិនបង្កទំនាស់ (DNH)

3. អន្តរាគមន៍មួយ មានទំនាក់ទំនង/អន្តរអំពើទាំងជាមួយកត្តាបែកបាក់ និងកត្តាផ្សារភ្ជាប់



# មេរៀនទាំង ៦ នៃឧបករណ៍មិនបង្កទំនាស់ (DNH)

4. សណ្ឋានផលជះអាចព្យាករណ៍ទុកមុនបានតាមរយៈអន្តរអំពើរវាងជំនួយ នឹងទំនាស់ (សកម្មភាព និង ឥរិយាបថបុគ្គលិក)



# មេរៀនទាំង ៦ នៃឧបករណ៍មិនបង្កទំនាស់ (DNH)

5. សេចក្តីលម្អិតនៃអន្តរាគមន៍របស់គម្រោង គឺជាបញ្ហា



# មេរៀនទាំង ៦ នៃឧបករណ៍មិនបង្កទំនាស់ (DNH)

## 6. ជម្រើសតែងតែមាន



# ក្របខណ្ឌនៃឧបករណ៍មិនបង្កទំនាស់ (DNH)



# ក្របខណ្ឌឧបករណ៍មិនបង្កទំនាស់សម្រាប់ការវិភាគពីផលជះរបស់ជំនួយលើទំនាស់



# ជំហានទាំង៧ នៃឧបករណ៍មិនបង្កគ្រោះថ្នាក់ធំនាស់



ករណីសិក្សា៖

# ឧបករណ៍មិនបង្កទំនាស់

## Do No Harm



ការនេសាទក្នុងឆកសមុទ្រកំពង់សោម ២០០៤

# ស្ថានភាព

- ក្នុង**ទស្សវត្ស៩០** មានអំពើហិង្សាមួយកើតឡើង និងបន្តរវាងក្រុមអ្នកនេសាទក្នុងឆកសមុទ្រកំពង់សោម។ **អ្នកនេសាទ ២២នាក់** ត្រូវបានគេសម្លាប់ក្នុងអំពើហិង្សានេះ។ ទោះបីជាយ៉ាងណា**ត្រឹមឆ្នាំ ២០០០** ស្ថានភាពហិង្សានេះ មានសភាពធូរស្បើយ។
- ក្នុងឆ្នាំ **១៩៩៧ អង្គការគណៈកម្មាធិការសេវាកម្មមិត្តភាពអាមេរិក (AFSC)** បានចាប់ផ្តើមអនុវត្តកម្មវិធីចិញ្ចឹមជីវិតក្នុងស្រុកស្រែអំបិល នៃតំបន់ឆកសមុទ្រកំពង់សោម។
- នៅដើម**ទស្សវត្សឆ្នាំ២០០០** កម្មវិធីរបស់អង្គការ AFSC បានចាប់ផ្តើមការងារទៅលើគម្រោងសហគមន៍នេសាទ ជាមួយអ្នកនេសាទស្រែអំបិល
- ក្នុងឆ្នាំ **២០០៤** អំពើហិង្សាថ្មីរវាងក្រុមអ្នកនេសាទក្នុងឆកសមុទ្រកំពង់សោមបានផ្ទុះឡើង។ កប៉ាល់នេសាទធំៗ ដែលមកពីសហគមន៍ផ្សេង បានចូលប្លន់ និងដុតបំផ្លាញផ្ទះសម្បែងអ្នកស្រែអំបិលខ្ទេចខ្ទីអស់។ ការិយាល័យកណ្តាលរបស់សហគមន៍នេសាទ ដែលគាំទ្រដោយ (AFSC) ត្រូវបានដុតបំផ្លាញចោលខ្ទេចខ្ទី។


Botum Sakor
ជីខក្រោម
Chikhor Krom
Srae Ambel
Chroy Svay
ជ្រោយស្វាយ
Khum Thma Sa
Chhak Kampong Som
Stung Hav
ស្ទឹងហាវ
Prey Nob
Krong Preah Sihanouk
ក្រុងព្រះសីហនុ

# ជំហានទី១៖ ស្វែងយល់ពីបរិបទនៃទំនាស់

តើអ្វីជាបរិបទ?

- សេដ្ឋកិច្ច
- សង្គម
- នយោបាយ
- វប្បធម៌
- ភូមិសាស្រ្ត
- បរិស្ថាន
- ..........



# ជំហានទី១៖ ស្វែងយល់ពីបរិបទនៃទំនាស់

- **តំបន់ទំនាស់៖**

  ក្រុមអ្នកនេសាទនៅជុំវិញឆកសមុទ្រកំពង់សោម

- **បរិបទទំនាស់៖**

  ការប្រកួតប្រជែងរបស់អ្នកនេសាទទៅលើធនធានជលផល ជាពិសេសរវាងអ្នកនេសាទតូចតាចក្នុងស្រុកស្រែអំបិល និងអ្នកនេសាទកប៉ាល់ធំៗមកពីស្ទឹងហាវ

# ជំហានទី១៖ ការវិភាគបរិបទ

១. បន្ទាត់ពេលវេលា



# ជំហានទី១៖ ការវិភាគបរិបទ

២. ផែនទីទំនាក់ទំនងក្នុងបរិបទ តើតួអង្គនៅក្នុងបរិបទមាន ទំនាក់ទំនងជាមួយគ្នាដូចម្តេចខ្លះ?




Source: Adapted from Fisher, et al. (2000: 23)

# ជំហានទី១៖ ការវិភាគបរិបទ

៣. វិភាគតួអង្គពាក់ព័ន្ធនៅក្នុងបរិបទ៖

| ក្រុម/ភាគី | បញ្ហា | ជំហរ | ផល ប្រយោជន៍ | តម្រូវការ | ឥទ្ធិពល/ អំណាច | ការត្រៀម ខ្លួនក្នុងការ ចរចា |
|---|---|---|---|---|---|---|
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |

# ឧបករណ៍ដែលអាចយកមកប្រើប្រាស់សម្រាប់ការវិភាគទំនាស់ដោយមានការចូលរួម

ឧបករណ៍វិភាគតាមបែបចូលរួមជាច្រើនប្រភេទ ត្រូវបានបង្កើតឡើងដោយអង្គការក្នុងស្រុក និងអន្តរជាតិ ដែលជាអ្នកអនុវត្តកម្មវិធីកសាងសន្តិភាព ហើយនឹងត្រូវបានយកមកប្រើប្រាស់ជាសកល (GPPAC 2015)។ ឧបករណ៍ទាំងនេះត្រូវបានគេចាត់ជាក្រុម ដោយយោងទៅតាមគោលបំណងចំបងៗរបស់វា និងចំណុចសំខាន់នៃការវិភាគ។ ឧបករណ៍មួយចំនួនត្រូវបានជ្រើសរើសយកមកបង្ហាញ ដោយបញ្ជាក់នូវគោលបំណង និងអត្ថប្រយោជន៍ ដូចខាងក្រោម៖

| ឈ្មោះឧបករណ៍ | គោលបំណង | អត្ថប្រយោជន៍ |
|---|---|---|
| ត្រីកោណ ABC<br>ABC Triangle | • ស្វែងយល់ពីបរិបទទំនាស់ តួអង្គសំខាន់ៗ អាកប្បកិរិយា និងឥរិយាបថរបស់ពួកគេ<br>• ប្រើនៅពេលចាប់ផ្តើមអន្តរាគមន៍របស់ភាគីទីពី ដើម្បីកំណត់កត្តាបង្កឲ្យមានទំនាស់នៃភាគីទំនាស់ និងអ្វីជាកត្តាដែលអាចចូលរួមចំណែកដោះស្រាយតាមរយៈអន្តរាគមន៍ | • បង្ហាញពីទំនាក់ទំនង និងអន្តរអំពើទៅវិញទៅមកនៃអាកប្បកិរិយា ឥរិយាបថ និង បរិបទ |
| ផែនទីតួអង្គ និងអ្នកពាក់ព័ន្ធ<br>Actors and Stakeholders Mapping | • ផ្តល់ទិដ្ឋភាពទូទៅនៃភាគីទំនាស់ និងអ្នកពាក់ព័ន្ធសំខាន់ៗ<br>    ○ អំណាច/ឥទ្ធិពលរបស់ពួកគេ និង<br>    ○ ទំនាក់ទំនងរបស់ពួកគេ | • បង្ហាញឲ្យឃើញពីទំនាក់ទំនងអំណាច និងភាពមិនស្មើគ្នារវាងភាគីទំនាស់<br>• ជួយកំណត់ចំណុចចាប់ផ្តើមនៃអន្តរាគមន៍និងតួអង្គដែលមានសក្តានុពល<br>• បញ្ជាក់ពីគោលជំហរ និងតួនាទីរបស់ស្ថាប័ន ជាពិសេសវាមានសារសំខាន់បំផុតនៅពេលចាប់ផ្តើម |
| ទំនាស់ខ្ទឹមបារាំង<br>Conflict Onion | • (មើលកាន់តែលម្អិត) ដោយប្រើសំណួរសំខាន់ៗមួយចំនួនស្តីពីទំនាស់ដូចជា តម្រូវការ ផលប្រយោជន៍ និងមុខងារ។ វាត្រូវបានប្រើប្រាស់ក្នុងការរៀបចំអន្តរាគមន៍របស់ភាគីទីពី។ | • បង្ហាញពីភាពខុសគ្នា និងទំនាក់ទំនងរវាងមុខងារ ផលប្រយោជន៍ និងតម្រូវការ<br>• ជួយអ្នកឲ្យយល់ពីចរិកលក្ខណៈនៃទំនាស់រ៉ាំរ៉ៃដែលមានរយៈពេលយូរ |
| ទំនាស់ពីរ៉ាមីត<br>Conflict Pyramid | • ផ្តល់ទិដ្ឋភាពទូទៅពីតួអង្គ និងអ្នកពាក់ព័ន្ធសំខាន់ៗដែលទាក់ទងនឹងការប្រែប្រួលនៃទំនាស់ ដោយយោងតាមអំណាចផ្លូវការ/ស្របច្បាប់របស់ពួកគេ ជាឥទ្ធិពលលើសកម្មភាពទំនាស់ (Conflict dynamics)<br>• សង្កត់ធ្ងន់លើតម្រូវការសម្រាប់ទំនាក់ទំនងដោយផ្ទាល់ និងដោយប្រយោលដើម្បី *(ភាពជោគជ័យ)* នៃការផ្លាស់ប្តូរទំនាស់ | • កំណត់តួអង្គសំខាន់ៗ និងភាពជាអ្នកដឹកនាំនៅគ្រប់កម្រិតនយោបាយ<br>• កំណត់សម្ព័ន្ធមិត្ត និងអ្នកសហការ ដែលមានសក្តានុពលនៅគ្រប់កម្រិតដឹកនាំ |
| ជំហាននៃទំនាស់<br>Conflict Stages | • កំណត់សកម្មភាពទំនាស់ និងទំនោរនៃការប្រែប្រួល (រីករាលដាល/ថយចុះ) នៃទំនាស់នាពេលខាងមុខ | • កំណត់វដ្ត និងដំណាក់កាលនៃការរីករាលដាល និងថយចុះនៃទំនាស់<br>• កំណត់ទំនោរនៃការរីករាលដាលនៃទំនាស់នាពេលខាងមុខ ដើម្បីបង្ការមិនឲ្យវាកើតមានឡើង (ផ្តល់ការព្រមានឲ្យបានលឿន និងឆ្លើយតបបានលឿន)<br>• ជួយពិភាក្សាពីស្ថានភាពបច្ចុប្បន្ន |

| ឈ្មោះឧបករណ៍ | គោលបំណង | អត្ថប្រយោជន៍ |
|---|---|---|
| បន្ទាត់ពេលវេលា<br>Conflict Timeline | • ប្រើប្រាស់ក្នុងអន្តរាគមន៍សម្រាប់ភាគីទី៣ ដូចជា ដំណើរការសម្របសម្រួល ឬ សម្រាប់ប្រជាពលរដ្ឋ<br>• បង្ហាញពីការគិតផ្សេងគ្នានៃប្រវត្តិសាស្ត្រទំនាស់ និងសកម្មភាពទំនាស់ | • សម្របសម្រួលការពិភាក្សាដែលមានគំនិតយោបល់ផ្សេងគ្នា ដោយផ្អែកលើការបកស្រាយខុសគ្នាលើប្រវត្តិសាស្ត្រ<br>• ចូលរួមជជែកពិភាក្សាស្តីពីគំនិតផ្សេងគ្នានៃព្រឹត្តិការប្រវត្តិសាស្ត្រ<br>• ជួយភាគីទំនាស់យល់ពីការគិតរបស់ពួកគេថាគ្រាន់តែជាមួយផ្នែកនៃការពិតរបស់ប្រវត្តិសាស្ត្រតែប៉ុណ្ណោះ |
| ដើមឈើទំនាស់<br>Conflict Tree | • ផ្តល់ទិដ្ឋភាពទូទៅពីកត្តាទំនាស់ចំបងៗ (ឫសគល់នៃបញ្ហា បញ្ហាទំនាស់ និង ផលជះរបស់វា) | • បង្ហាញពីទំនាក់ទំនងយ៉ាងជិតស្និទ្ធ និងអន្តរអំពើនៃឫសគល់ទំនាស់ បញ្ហា និងផលជះរបស់វា<br>• ជួយចាត់អទិភាពសកម្មភាពមួយ ដែលអាចជួយដោះស្រាយបញ្ហាទំនាស់ |
| ឧបករណ៍មិនបង្កទំនាស់/ការវិភាគផលជះ<br>Do No Harm/Impact Analysis | • វាយតម្លៃបរិបទទំនាស់ (កត្តាបែកបាក់ និងកត្តាផ្សារភ្ជាប់) និង ផលជះអវិជ្ជមានដែល (ស្មានមិនដល់) របស់គម្រោង (សកម្មភាព/ដំណើរការលម្អិត) ទៅលើបរិបទទំនាស់ | • ជួយកាត់បន្ថយភាពស្មុគ្រស្មាញនៃទំនាស់<br>• ជួយកាត់បន្ថយផលជះអវិជ្ជមាន (ស្មានមិនដល់) ជាអប្បបរមា និង បង្កើនផលជះវិជ្ជមាន (ដែលចង់បាន)របស់គម្រោង ឲ្យដល់កម្រិតអតិបរមា |
| Force Field Analysis | • ផ្តល់ទិដ្ឋភាពទូទៅទៅលើកត្តាបង្កឲ្យមានទំនាស់ និងកត្តាប្រឆាំងនឹងទំនាស់ | • ជួយរៀបចំព័ត៌មានស្តីពីស្ថានភាពទំនាស់បច្ចុប្បន្ន<br>• ផ្តល់នូវទិដ្ឋភាពកាន់តែច្បាស់ពីកត្តាបង្កឲ្យមានទំនាស់ និងកត្តាប្រឆាំងនឹងទំនាស់<br>• ជួយចាត់អទិភាព កត្តាបង្កឲ្យមានទំនាស់ និងប្រឆាំងនឹងទំនាស់ |
| តារាងផលប្រយោជន៍ តម្រូវការ និងភាពភ័យខ្លាច<br>Interests, Needs and Fears Chart | • (មើលកាន់តែលម្អិត) ដោយប្រើសំណួរសំខាន់ៗមួយចំនួនស្តីពីទំនាស់ដូចជា តម្រូវការ ផលប្រយោជន៍ និងមុខងារ។ វាត្រូវបានប្រើប្រាស់ក្នុងការរៀបចំអន្តរាគមន៍របស់ភាគីទី៣។ | • ជួយភាគីទំនាស់ឲ្យយល់ពីតម្រូវការ និងភាពភ័យខ្លាចដែលមិនអាចមើលឃើញនឹងភ្នែក ដែលនៅពីក្រោយផលប្រយោជន៍ និងមុខងារ<br>• បង្ហាញពីទំនាក់ទំនងយ៉ាងជិតស្និទ្ធ និងអន្តរអំពើនៃបញ្ហាទំនាស់ បរិបទ និងតម្រូវការ និងផលប្រយោជន៍នៃភាគីទំនាស់ |
| ការវិភាគទំនាស់ជាលក្ខណៈប្រព័ន្ធ/ផែនទីប្រព័ន្ធ<br>Systemic Conflict Analysis/Systems Mapping | • កំណត់ចំណុចចាប់ផ្តើមជាយុទ្ធសាស្ត្រសម្រាប់យុទ្ធសាស្ត្រកសាងសន្តិភាព ឬកម្មវិធី<br>• ផ្តល់នូវការវិភាគជាលក្ខណៈមូលដ្ឋានសម្រាប់ការបង្កើតសេណារីយ៉ូ/ព្យាករណ៍ទំនាស់ ឬ វាយតម្លៃភាពប្រថុយប្រថាន | • ជួយដល់ការស្វែងយល់ និងពន្យល់ពីទំនាក់ទំនង/អន្តរអំពើ (ភាពត្រឹម/ខុសបន្លាយ) នៃទំនាស់ហិង្សា និងសង្គម<br>• បន្តកំណត់សកម្មភាពទំនាស់ជាលក្ខណៈឡែក្រង់ និង បត់បែនឡើងចុះព្រមទាំងទំនាក់ទំនង និងសកម្មភាពនៃកត្តាទំនាស់ទាំងនេះ |

# ជំហានទី២៖ ការវិភាគកត្តាបែកបាក់

- កត្តាបែកបាក់ ជាឫសគល់ ឬ អ្វីដែលបង្កើន៖
  - ភាពតានតឹង
  - ការសង្ស័យ
  - ភាពមិនទុកចិត្តគ្នា
  - សមត្ថភាពបង្កឲ្យមានទំនាស់ ឬ ហិង្សារវាងក្រុមមនុស្ស



- នៅក្នុងបរិបទទំនាស់ចំហរ កត្តាបែកបាក់មានភាពលេចធ្លោ យើងអាចឃើញ ឬ ស្តាប់លឺគេនិយាយអំពីវា
- នៅក្នុងបរិបទទំនាស់បង្កប់ កត្តាបែកបាក់នៅតែមាន ហើយអាចនាំទៅដល់អំពើហឹង្សា តែអ្នកក្រៅអាចមិនមើលឃើញជាក់ស្តែងទេ

# ជំហានទី៣៖ ការវិភាគកត្តាផ្សាភ្ជាប់

- កត្តាផ្សាភ្ជាប់ជាមូលហេតុ ឬ អ្វីដែលធ្វើឱ្យ៖
    - មនុស្សនៅជាមួយគ្នា
    - បង្កើនការទុកចិត្តគ្នា
    - ពឹងអាស្រ័យគ្នាទៅវិញទៅមក
    - កាត់បន្ថយភាពមិនស្មើគ្នា



- នៅក្នុងបរិបទដែលមានទំនាស់ កត្តាផ្សាភ្ជាប់ពិបាកនឹងមើលឃើញ ហើយជាទូទៅមិនត្រូវបានគេនិយាយដល់ តែវានៅតែមាន ហើយសំខាន់ទៀតផង។

# ប្រភេទទាំង៥ នៃកត្តាបែកបាក់ និង កត្តាផ្សារភ្ជាប់

ប្រព័ន្ធ និង ស្ថាប័ន

(Systems & Institutions)

ឥរិយាបថ និង សកម្មភាព

(Attitudes & Actions)




និមិត្តរូប និង ព្រឹត្តិការណ៍

(Symbols & Occasions)

គុណតម្លៃ និង ផលប្រយោជន៍

(Values & Interests)

បទពិសោធន៍

(Experiences)

# ប្រព័ន្ធ និង ស្ថាប័ន






# ឥរិយាបថ និង សកម្មភាព





# គុណតម្លៃ និង ផលប្រយោជន៍





# បទពិសោធន៍





# និមិត្តរូប និង ព្រឹត្តិការណ៍





# ជំហានទី២&៣៖ តើវាជា កត្តាបែកបាក់ ឬ កត្តាផ្សាភ្ជាប់ ឬ ទាំងពីរ?

1. គិតផលប្រយោជន៍រួមទៅលើនិរន្តរភាពនៃការនេសាទ (ប្រសិនបើត្រីបាត់បង់អស់ គ្រប់គ្នានឹងរងគ្រោះ)
2. កប៉ាល់នេសាទខុសច្បាប់ធំៗ (ពីស្ទឹងហាវ) ធ្វើការនេសាទក្នុងតំបន់ទឹករាក់ ធ្វើឲ្យត្រីថយចុះ។
3. អ្នកនេសាទតូចតាច (ពីស្រែអំបិល) លួចត្រីពីសំណាញ់កប៉ាល់នេសាទធំៗ
4. ការគ្រប់គ្រងតំបន់មិនបានល្អរបស់រដ្ឋាភិបាល (ការជួញដូរសត្វព្រៃ និងកាប់ឈើខុសច្បាប់ជាញឹកញាប់)
5. គ្មានច្បាប់ដើម្បីគ្រប់គ្រងសហគមន៍នេសាទ
6. រដ្ឋាភិបាលកំពុងព្រាងច្បាប់ស្ដីពីសហគមន៍នេសាទ ដោយមានការពិគ្រោះយោបល់ជាមួយអង្គការ និងសហគមន៍នេសាទ

# ដំណាក់ទី២&៣៖ តើវាជា កត្តាបែកបាក់ ឬ កត្តាផ្សារភ្ជាប់ ឬ ទាំងពីរ?

7. អភិបាលខេត្តមានអំណាច និងឥទ្ធិពលក្នុងការប្រមូលអ្នកពាក់ព័ន្ធមកពិភាក្សារួមគ្នា
8. អង្គការមានបណ្តាញរឹងមាំល្អ និងទទួលបានការគោរពពីសហគមន៍
9. អង្គការផ្សេងគ្នា ធ្វើការជាមួយសហគមន៍ផ្សេងគ្នា ហើយម្ខាងៗយល់តែពីបញ្ហា/ទំនាស់របស់ភាគីតែម្ខាង
10. ក្រុមអ្នកនេសាទចំណូលថ្មី បានកំណត់សហគមន៍របស់ពួកគេដោយខ្លួនឯង ហើយមានទំនាក់ទំនងតិចតួចបំផុតរវាងសហគមន៍
11. ពាក្យចចាមអារ៉ាម (ឧទា៖ ស្តីអំពីអ្នកនេសាទស្រែអំបិល បានចាប់ជម្រិតអ្នកនេសាទស្ទឹងហាវ) បង្កឱ្យមានអំពើហិង្សាកាន់តែធ្ងន់ធ្ងរឡើងៗ
12. ផ្ទះសម្បែងរបស់សហគមន៍នេសាទ គឺជានិមិត្តរូបនៃអំណាចរបស់ក្រុមសហគមន៍នេសាទ និងគោលដៅសម្រាប់ការវាយប្រហារ
13. ប្រជាជនគ្រប់ភាគីទំនាស់ និយាយភាសាតែមួយ និងមានជំនឿ ប្រពៃណី សាសនាតែមួយ

# កត្តាបែកបាក់ និង កត្តាផ្សារភ្ជាប់

- កត្តាបែកបាក់ មិនប្រាកដជាអវិជ្ជមាន ហើយកត្តាផ្សារភ្ជាប់ មិនប្រាកដជាវិជ្ជមាននោះទេ
- នៅពេលពិចារណា «បុគ្គល» ណាម្នាក់ ជាកត្តាបែកបាក់ ឬ កត្តាផ្សារភ្ជាប់ គួរជ្រើសរើស ឥរិយាបថ / សកម្មភាព ព្រោះមនុស្សប្រែប្រួលឆាប់រហ័ស
- នៅពេលដែលអ្វីមួយហាក់ដូចជា កត្តាបែកបាក់ផង កត្តាផ្សារភ្ជាប់ផង ព្យាយាមលម្អិតវាបន្ថែម ដើម្បីងាយក្នុងការកំណត់
- កំណត់ព្រំដែនរបស់កត្តាបែកបាក់ ឬ កត្តាផ្សារភ្ជាប់
- ការចាត់អាទិភាពកត្តាបែកបាក់ និង កត្តាផ្សារភ្ជាប់៖
  - តើកត្តាបែកបាក់ណាខ្លះដែលគ្រោះថ្នាក់បំផុត ឬ បង្កើនភាពតានតឹងរវាងក្រុមមនុស្សបំផុត?
  - តើកត្តាផ្សារភ្ជាប់ណាខ្លះដែលយើងអាចប្រើប្រាស់ដើម្បីបង្កើនផលជះវិជ្ជមាន?